**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១១..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុងព្រះវិហារ នៃខេត្តព្រះវិហារ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុងព្រះវិហារ នៃខេត្តព្រះវិហារ ដោយកាត់យកឃុំចំនួនពីរគឺ ឃុំកំពង់ប្រណាក និង ឃុំប៉ាលហាល ពីស្រុកត្បែងមានជ័យ នៃខេត្តព្រះវិហារ ។

www.pheakdeylaw.com

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងព្រះវិហារ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្តូរឃុំ ចំនួនពីរនៃ **ក្រុងព្រះវិហារ** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំកំពង់ប្រណាក | ទៅជា | សង្កាត់កំពង់ប្រណាក |
| ២- ឃុំប៉ាលហាល | ទៅជា | សង្កាត់ប៉ាលហាល |

មាត្រា ៣.-

ត្រូវផ្ទេរទីតាំងសាលាស្រុកត្បែងមានជ័យ ដែលស្ថិតនៅក្នុងសង្កាត់កំពង់ប្រណាក ទៅជាសាលា **ក្រុងព្រះវិហារ** ។

មាត្រា ៤.-

ទីតាំងសាលាស្រុកត្បែងមានជ័យ ត្រូវស្ថិតនៅក្នុងឃុំប្រមេរុ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

មាត្រា ៥.-

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រង **ក្រុងព្រះវិហារ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រះវិហារ អភិបាលក្រុងព្រះវិហារ អភិបាលស្រុកត្បែងមានជ័យ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

# ផែនទីបង្ហាញទីតាំងប្លង់ក្រុងព្រះវិហារ និងតំបន់រដ្ឋបាលទីប្រជុំជនស្រុកត្បែងមានជ័យ

## ខេត្តព្រះវិហារ




លេខ : ១៤១ សជណ

បានឃើញ និងឯកភាព

ព្រះវិហារ, ថ្ងៃទី១៧ខែធ្នូ....ឆ្នាំ២០០៨

អភិបាលខេត្តព្រះវិហារ

ព្រាប_តាន់

លេខ : ០០៥ ...

បានឃើញ និង ឯកភាព

ភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

លេខ :........២៣២........ដ.ន.ស.ស

ត្បែងមានជ័យ, ថ្ងៃទី១៧ ខែធ្នូ.....ឆ្នាំ២០០៨

សិក្សាដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះវិហារ

គង់_សោភ័ណ

www.pheakdeylaw.com